# C87 Freedom of Association and Protection of the Right to Organise Convention, 1948

*Convention concerning Freedom of Association and Protection of the Right to Organise (Note: Date of coming into force: 04:07:1950.) Convention:C087 Place:(San Francisco) Session of the Conference:31 Date of adoption:09:07:1948 Subject classification: Freedom of Association Subject classification: Collective Bargaining and Agreements Subject:* ***Freedom of Association, Collective Bargaining, and Industrial Relations*** *See the ratifications for this Convention Display the document in: French Spanish Status: Up-to-date instrument This instrument is one of the fundamental conventions.*

The General Conference of the International Labour Organisation,

Having been convened at San Francisco by the Governing Body of the International Labour Office, and having met in its Thirty-first Session on 17 June 1948;

Having decided to adopt, in the form of a Convention, certain proposals concerning freedom of association and protection of the right to organise, which is the seventh item on the agenda of the session;

Considering that the Preamble to the Constitution of the International Labour Organisation declares "recognition of the principle of freedom of association" to be a means of improving conditions of labour and of establishing peace;

Considering that the Declaration of Philadelphia reaffirms that "freedom of expression and of association are essential to sustained progress";

Considering that the International Labour Conference, at its Thirtieth Session, unanimously adopted the principles which should form the basis for international regulation;

Considering that the General Assembly of the United Nations, at its Second Session, endorsed these principles and requested the International Labour Organisation to continue every effort in order that it may be possible to adopt one or several international Conventions;

adopts this ninth day of July of the year one thousand nine hundred and forty-eight the following Convention, which may be cited as the Freedom of Association and Protection of the Right to Organise Convention, 1948:

## PART I. FREEDOM OF ASSOCIATION

### Article 1

Each Member of the International Labour Organisation for which this Convention is in force undertakes to give effect to the following provisions.

### Article 2

Workers and employers, without distinction whatsoever, shall have the right to establish and, subject only to the rules of the organisation concerned, to join organisations of their own choosing without previous authorisation.

### Article 3

1. Workers' and employers' organisations shall have the right to draw up their constitutions and rules, to elect their representatives in full freedom, to organise their administration and activities and to formulate their programmes.

2. The public authorities shall refrain from any interference which would restrict this right or impede the lawful exercise thereof.

### Article 4

Workers' and employers' organisations shall not be liable to be dissolved or suspended by administrative authority.

### Article 5

Workers' and employers' organisations shall have the right to establish and join federations and confederations and any such organisation, federation or confederation shall have the right to affiliate with international organisations of workers and employers.

## Article 6

The provisions of Articles 2, 3 and 4 hereof apply to federations and confederations of workers' and employers' organisations.

## Article 7

The acquisition of legal personality by workers' and employers' organisations, federations and confederations shall not be made subject to conditions of such a character as to restrict the application of the provisions of Articles 2, 3 and 4 hereof.

## Article 8

1. In exercising the rights provided for in this Convention workers and employers and their respective organisations, like other persons or organised collectivities, shall respect the law of the land.

2. The law of the land shall not be such as to impair, nor shall it be so applied as to impair, the guarantees provided for in this Convention.

## Article 9

1. The extent to which the guarantees provided for in this Convention shall apply to the armed forces and the police shall be determined by national laws or regulations.

2. In accordance with the principle set forth in paragraph 8 of Article 19 of the Constitution of the International Labour Organisation the ratification of this Convention by any Member shall not be deemed to affect any existing law, award, custom or agreement in virtue of which members of the armed forces or the police enjoy any right guaranteed by this Convention.

## Article 10

In this Convention the term ***organisation*** means any organisation of workers or of employers for furthering and defending the interests of workers or of employers.

# PART II. PROTECTION OF THE RIGHT TO ORGANISE

## Article 11

Each Member of the International Labour Organisation for which this Convention is in force undertakes to take all necessary and appropriate measures to ensure that workers and employers may exercise freely the right to organise.

# PART III. MISCELLANEOUS PROVISIONS

## Article 12

1.In respect of the territories referred to in Article 35 of the Constitution of the International Labour Organisation as amended by the Constitution of the International Labour Organisation Instrument of Amendment 1946, other than the territories referred to in paragraphs 4 and 5 of the said article as so amended, each Member of the Organisation which ratifies this Convention shall communicate to the Director-General of the International Labour Office with or as soon as possible after its ratification a declaration stating:

a) the territories in respect of which it undertakes that the provisions of the Convention shall be applied without modification;

b) the territories in respect of which it undertakes that the provisions of the Convention shall be applied subject to modifications, together with details of the said modifications;

c) the territories in respect of which the Convention is inapplicable and in such cases the grounds on which it is inapplicable;

d) the territories in respect of which it reserves its decision.

2. The undertakings referred to in subparagraphs (a) and (b) of paragraph 1 of this Article shall be deemed to be an integral part of the ratification and shall have the force of ratification.

3. Any Member may at any time by a subsequent declaration cancel in whole or in part any reservations made in its original declaration in virtue of subparagraphs (b), (c) or (d) of paragraph 1 of this Article.

4. Any Member may, at any time at which the Convention is subject to denunciation in accordance with the provisions of Article 16, communicate to the Director-General a declaration modifying in any other respect the terms of any former declaration and stating the present position in respect of such territories as it may specify.

### Article 13

1. Where the subject-matter of this Convention is within the self-governing powers of any non-metropolitan territory, the Member responsible for the international relations of that territory may, in agreement with the government of the territory, communicate to the Director-General of the International Labour Office a declaration accepting on behalf of the territory the obligations of this Convention.

2. A declaration accepting the obligations of this Convention may be communicated to the Director-General of the International Labour Office:

a) by two or more Members of the Organisation in respect of any territory which is under their joint authority; or

b) by any international authority responsible for the administration of any territory, in virtue of the Charter of the United Nations or otherwise, in respect of any such territory.

3. Declarations communicated to the Director-General of the International Labour Office in accordance with the preceding paragraphs of this Article shall indicate whether the provisions of the Convention will be applied in the territory concerned without modification or subject to modifications; when the declaration indicates that the provisions of the Convention will be applied subject to modifications it shall give details of the säid modifications.

4. The Member, Members or international authority concerned may at any time by a subsequent declaration renounce in whole or in part the right to have recourse to any modification indicated in any former declaration.

5. The Member, Members or international authority concerned may, at any time at which this Convention is subject to denunciation in accordance with the provisions of Article 16, communicate to the Director-General a declaration modifying in any other respect the terms of any former declaration and stating the present position in respect of the application of the Convention.

## PART IV. FINAL PROVISIONS

### Article 14

The formal ratifications of this Convention shall be communicated to the Director-General of the International Labour Office for registration.

### Article 15

1. This Convention shall be binding only upon those Members of the International Labour Organisation whose ratifications have been registered with the Director-General.

2. It shall come into force twelve months after the date on which the ratifications of two Members have been registered with the Director-General.

3. Thereafter, this Convention shall come into force for any Member twelve months after the date on which its ratifications has been registered.

### Article 16

1. A Member which has ratified this Convention may denounce it after the expiration of ten years from the date on which the Convention first comes into force, by an act communicated to the Director-General of the International Labour Office for registration. Such denunciation shall not take effect until one year after the date on which it is registered.

2. Each Member which has ratified this Convention and which does not, within the year following the expiration of the period of ten years mentioned in the preceding paragraph, exercise the right of denunciation provided for in this Article, will be bound for another period of ten years and, thereafter, may denounce this Convention at the expiration of each period of ten years under the terms provided for in this Article.

### Article 17

1. The Director-General of the International Labour Office shall notify all Members of the International Labour Organisation of the registration of all ratifications, declarations and denunciations communicated to him by the Members of the Organisation.

2. When notifying the Members of the Organisation of the registration of the second ratification communicated to him, the Director-General shall draw the attention of the Members of the Organisation to

the date upon which the Convention will come into force.

### Article 18

The Director-General of the International Labour Office shall communicate to the Secretary-General of the United Nations for registration in accordance with Article 102 of the Charter of the United Nations full particulars of all ratifications, declarations and acts of denunciation registered by him in accordance with the provisions of the preceding articles.

### Article 19

At such times as it may consider necessary the Governing Body of the International Labour Office shall present to the General Conference a report on the working of this Convention and shall examine the desirability of placing on the agenda of the Conference the question of its revision in whole or in part.

### Article 20

1. Should the Conference adopt a new Convention revising this Convention in whole or in part, then, unless the new Convention otherwise provides:

a) the ratification by a Member of the new revising Convention shall ipso jure involve the immediate denunciation of this Convention, notwithstanding the provisions of Article 16 above, if and when the new revising Convention shall have come into force;

b) as from the date when the new revising Convention comes into force this Convention shall cease to be open to ratification by the Members.

2. This Convention shall in any case remain in force in its actual form and content for those Members which have ratified it but have not ratified the revising Convention.

### Article 21

The English and French versions of the text of this Convention are equally authoritative.

**Cross references** CONSTITUTION:P:Preamble to the Constitution of the International Labour Organisation Constitution: 19:article 19 of the Constitution of the International Labour Organisation Constitution: 35:article 35 of the Constitution of the International Labour Organisation

# អនុសញ្ញាលេខ ៨៧
# ស្តីពី
# សេរីភាពនៃសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម[១]

## សន្និសីទសាកលនៃអង្គការអន្តរជាតិខាងការងារ

បានឃើញការកោះប្រជុំនៅទីក្រុងហ្សឺណែវដោយក្រុមប្រឹក្សាភិបាលនៃការិយាល័យអន្តរជាតិខាងការងារ និងបានបើកសម័យប្រជុំលើកទី សាមសិបមួយរបស់ខ្លួននាថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ១៩៤៨។

បានឃើញការយល់ព្រមចាត់ទុកសំណើមួយចំនួនស្តីអំពីសេរីភាពនៃសមាគម និងការការពារសិទ្ធិបង្កើតសមាគមក្នុងទម្រង់ជាអនុសញ្ញា ព្រមទាំងបញ្ចូលសំណើទាំងនោះទៅក្នុងចំណុចទីប្រាំពីរនៃរបៀបវារៈរបស់សម័យប្រជុំនេះ។

បានឃើញបុព្វកថានៃធម្មនុញ្ញរបស់អង្គការអន្តរជាតិខាងការងារដែលប្រកាសថា "ការទទួលស្គាល់នូវគោលការណ៍ស្តីពីសេរីភាពនៃសមាគម" គឺបានដល់មធ្យោបាយនៃការកែលំអលក្ខខណ្ឌការងារ និងការបង្កើតនូវសន្តិភាព។

បានឃើញសេចក្តីប្រកាសហ្វីឡាដែលហ្វីយ៉ា ដែលបញ្ជាក់ថា "សេរីភាពនៃការសំដែងមតិ និងសេរីភាពនៃសមាគម គឺមានសារៈសំខាន់សម្រាប់ការទ្រទ្រង់ឱ្យមានវឌ្ឍនធម៌"។

បានឃើញសេចក្តីព្រមព្រៀងជាឯកច្ឆន្ទរបស់សន្និសីទសាកលនៃអង្គការអន្តរជាតិខាងការងារលើកទីសាមសិប ដែលកំណត់ថាគោលការណ៍ទាំងនោះគួរមានទម្រង់ជាច្បាប់អន្តរជាតិ។ បានឃើញសម័យប្រជុំលើកទីពីរនៃមហាសន្និបាតរបស់អង្គការសហប្រជាជាតិ ដែលបានសំរេចគាំទ្រគោលការណ៍ទាំងនេះ ព្រមទាំងបានស្នើឱ្យអង្គការអន្តរជាតិខាងការងារបន្តការខិតខំប្រឹងប្រែងដើម្បីអាចមានលទ្ធភាពអនុម័តអនុសញ្ញាអន្តរជាតិបានមួយ ឬច្រើនថែមទៀត។

អនុម័តនៅថ្ងៃទីប្រាំបួន ខែកក្កដា ឆ្នាំមួយពាន់ប្រាំបួនរយសែសិបប្រាំបីនូវអនុសញ្ញានេះដែលតទៅហៅថា អនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីសេរីភាពនៃសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម៖

---

១. កាលបរិច្ឆេទនៃការចូលជាធរមាន : ៤ កក្កដា ១៩៥០

# ផ្នែកទី ១
# សេរីភាពនៃសមាគម

## មាត្រា ១

ចាប់ពីពេលដែលអនុសញ្ញានេះបានចូលជាធរមានតទៅ ប្រទេសជាសមាជិកនីមួយៗ នៃអង្គការអន្តជាតិខាងការងារដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ ត្រូវទទួលខុសត្រូវធ្វើឱ្យមានប្រសិទ្ធិភាពនូវបទប្បញ្ញត្តិទាំងឡាយដូចមានចែងក្នុងមាត្រាជាបន្តបន្ទាប់ខាងក្រោម។

## មាត្រា ២

ដោយមិនមានការបែងចែកអ្វីទាំងអស់ កម្មករនិយោជិត និងនិយោជក មានសិទ្ធិបង្កើតសមាគម លើកលែងតែការគោរពបទបញ្ញាផ្ទៃក្នុងនៃអង្គការសាមីចេញ ក៏មានសិទ្ធិចូលរួមក្នុងសមាគមតាមការជ្រើសរបស់ខ្លួន និងដោយមិនបាច់មានសុំការអនុញ្ញាតជាមុនឡើយ។

## មាត្រា ៣

១. អង្គការនៃកម្មករនិយោជិត និងអង្គការនិយោជកមានសិទ្ធិតាក់តែងលក្ខន្តិកៈ និងបទបញ្ញាផ្សេងៗបោះឆ្នោតជ្រើសរើសអ្នកតំណាងរបស់ខ្លួនដោយសេរី និងចាត់ចែងរៀបចំរដ្ឋបាល និងសកម្មភាពរបស់ខ្លួន ព្រមទាំងមានសិទ្ធិរៀបចំកម្មវិធីសកម្មភាពនានារបស់ខ្លួនដោយខ្លួនឯង។

២. អាជ្ញាធរសាធារណៈត្រូវរាំងស្កាត់នូវរាល់អំពើជ្រៀតជ្រែកនានា ដែលអាចកំរិត ឬក៏បង្អាក់ការអនុវត្តន៍ដោយពេញលេញតាមច្បាប់អំពីសិទ្ធិនេះ។

## មាត្រា ៤

អង្គការកម្មករនិយោជិត និងអង្គការនិយោជកមិនអាចត្រូវបានរំលាយ ឬព្យួរដោយអាជ្ញាធររដ្ឋបាលឡើយ។

## មាត្រា ៥

អង្គការកម្មករនិយោជិត និងអង្គការនិយោជកមានសិទ្ធិបង្កើត ឬចូលរួមក្នុងសហព័ន្ធ ឬសម្ព័ន្ធ ហើយអង្គការ ឬសហព័ន្ធ ឬសម្ព័ន្ធទាំងនេះក៏មានសិទ្ធិចងសម្ព័ន្ធជាមួយនឹងអង្គការអន្តរជាតិនៃកម្មករ-និយោជិត និងអង្គការអន្តរជាតិនៃនិយោជកដែរ។

## មាត្រា ៦

បទប្បញ្ញត្តិក្នុងមាត្រា ២ មាត្រា ៣ មាត្រា ៤ នៃអនុសញ្ញានេះក៏ត្រូវអនុវត្តចំពោះសហព័ន្ធ និងសម្ព័ន្ធនៃអង្គការកម្មករនិយោជិត និងអង្គការនិយោជកផងដែរ។

## មាត្រា ៧

បុគ្គលិកលក្ខណៈតាមច្បាប់នៃអង្គការកម្មករនិយោជិត អង្គការនិយោជក ឬសហព័ន្ធ និងសម្ព័ន្ធនៃអង្គការទាំងនេះ មិនអាចជាមូលហេតុនាំឱ្យមានការដាក់កំរិតនៃការអនុវត្តន៍បទប្បញ្ញត្តិក្នុងមាត្រា ២ មាត្រ ៣ និង មាត្រា ៤ នៃអនុសញ្ញានេះឡើយ។

## មាត្រា ៨

១. ក៏ដូចជាប្រជាពលរដ្ឋ ឬអង្គការសមូហភាពនានាដែរ នៅក្នុងការអនុវត្តន៍សិទ្ធិដូចមានចែងក្នុងបទប្បញ្ញត្តិនៃអនុសញ្ញានេះ កម្មករនិយោជិត និងនិយោជក ព្រមទាំងអង្គការរបស់ខ្លួនត្រូវគោរពច្បាប់នៃដែនដី។

២. ច្បាប់នៃដែនដីមិនត្រូវធ្វើឱ្យមានការចុះខ្សោយ ឬមិនត្រូវបានគេយកទៅអនុវត្តដើម្បីធ្វើឱ្យមានការថមថយដល់ការធានារ៉ាប់រងទាំងឡាយដូចដែលមានចែងនៅក្នុងអនុសញ្ញានេះ។

## មាត្រា ៩

១. វិសាភាពនៃការធានារ៉ាប់រងដែលចែងក្នុងអនុសញ្ញានេះ អាចអនុវត្តចំពោះកងកម្លាំងប្រដាប់អាវុធ និងកងនគរបាល ហើយដែលវិសាលភាពនេះត្រូវបានកំណត់ដោយច្បាប់ ឬគោលការណ៍នានារបស់ជាតិ។

២. អនុលោមតាមគោលការណ៍ដែលមានចែងនៅក្នុងកថាខណ្ឌ ៨ មាត្រា ១៩ នៃធម្មនុញ្ញរបស់អង្គការអន្តរជាតិខាងការងារ ការផ្តល់សច្ចាប័នចំពោះអនុសញ្ញានេះដោយប្រទេសជាសមាជិកណាមួយមិនអាចជាផលប៉ះពាល់ចំពោះច្បាប់ សេចក្តីសំរេចរបស់តុលាការ ទំនៀមទម្លាប់ ឬកិច្ចព្រមព្រៀងជាធរមាន ដែលតាមច្បាប់ទាំងនោះ សមាជិកនានានៃកងកម្លាំងប្រដាប់អាវុធ ឬកងនគរបាលអាចទទួលនូវសិទ្ធិណាមួយ ដែលបានធានាដោយអនុសញ្ញានេះ។

## មាត្រា ១០

នៅក្នុងអនុសញ្ញានេះ ពាក្យថា "អង្គការ" មានន័យថា អង្គការនៃកម្មករ-និយោជិត ឬអង្គការនិយោជកដែលមានគោលដៅដើម្បីលើកស្ទួយ និងការពារអត្ថប្រយោជន៍នៃកម្មករ-និយោជិត ឬនិយោជក។

## ផ្នែកទី ២

## សិទ្ធិក្នុងការបង្កើតសមាគម

[illegible]

នៅពេលដែលអនុសញ្ញានេះចូលជាធរមាន ប្រទេសជាសមាជិកនីមួយៗនៃអង្គការអន្តរជាតិខាងការងារត្រូវទទួលខុសត្រូវដាក់ចេញនូវរាល់វិធានការដែលចាំបាច់ និងសមស្រប ដើម្បីធានាឱ្យនិយោជិត កម្មករ និងនិយោជកអាចអនុវត្តបានដោយសេរីនូវសិទ្ធិក្នុងការបង្កើតសមាគម។

## ផ្នែកទី ៣

## បទប្បញ្ញត្តិផ្សេងៗ

[illegible]

១. ទាក់ទងទៅនឹងដែនដីចំណុះដែលយោងតាមមាត្រា ៣៥ នៃធម្មនុញ្ញរបស់អង្គការអន្តរជាតិខាងការងារ ហើយដែលបានធ្វើវិសោធនកម្មដោយលិខិតូបករណ៍វិសោធនកម្មនៃធម្មនុញ្ញរបស់អង្គការអន្តរជាតិខាងការងារនៅឆ្នាំ ១៩៤៦ លើកលែងតែបណ្តាដែនដីដែលអនុលោមតាមកថាខណ្ឌ ៤ និង ៥ នៃមាត្រាខាងលើ ប្រទេសជាសមាជិកនីមួយៗដែលផ្តល់សច្ចាប័នចំពោះអនុសញ្ញានេះ ត្រូវជូនផ្ញើទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារជាបន្ទាន់ បន្ទាប់ពីការផ្តល់សច្ចាប័ននោះមកនូវសេចក្តីប្រកាសអំពី៖

(ក) ដែនដីចំណុះ ដែលបទប្បញ្ញត្តិនៃអនុសញ្ញានេះត្រូវបានគេអនុវត្តដោយមិនមានការកែប្រែ។

(ខ) ដែនដីចំណុះ ដែលបទប្បញ្ញត្តិនៃអនុសញ្ញានេះត្រូវបានគេអនុវត្តដោយមានការកែប្រែ ដោយមានភ្ជាប់មកជាមួយនូវសេចក្តីអធិប្បាយពិស្តារអំពីការកែប្រែទាំងនោះផង។

(គ) ដែនដីចំណុះ ដែលអនុសញ្ញានេះមិនអាចអនុវត្តបាន។ ក្នុងករណីនេះត្រូវបង្ហាញពីមូលហេតុដែលមិនអាចឱ្យអនុសញ្ញានេះអនុវត្តបាន។

(ឃ) ដែនដីចំណុះ ដែលខ្លួនត្រូវរក្សាទុក។

២. ការព្រមព្រៀងដូចមានចែងក្នុងវាក្យខ័ណ្ឌ (ក) និង (ខ) នៃកថាខណ្ឌ ១ នៃមាត្រានេះ ត្រូវបានគេចាត់ទុកថាជាផ្នែកបតិដ្ឋាប័ននៃការផ្តល់សច្ចាប័នលើអនុសញ្ញានេះ ហើយក៏ត្រូវមានអំណាចក្នុងការផ្តល់សច្ចាប័នដែរ។

៣. ប្រទេសជាសមាជិកណាក៏ដោយអាចធ្វើសេចក្តីប្រកាសជាបន្តបន្ទាប់នៅពេលណាក៏បាន ដើម្បីបដិសេធដោយផ្នែក ឬទាំងស្រុងនូវការរក្សាទុកទាំងឡាយដែលបានធ្វើនៅក្នុងសេចក្តីប្រកាសដើមរបស់ខ្លួនដូចដែលមានចែងក្នុងកថាខណ្ឌរង (ខ) (គ) ឬ (ឃ) នៃកថាខណ្ឌ ១ នៃមាត្រានេះ។

៤. ប្រទេសជាសមាជិកណាក៏ដោយ ត្រូវធ្វើសេចក្តីប្រកាសអំពីការកែប្រែ ទោះក្នុងប្រការណាក៏ដោយនូវសេចក្តីសំរេចនៃសេចក្តីប្រកាសចាស់ ព្រមទាំងគូសបញ្ជាក់អំពីស្ថានភាពបច្ចុប្បន្នដែលទាក់ទងទៅនឹងដែនដីសហព័ន្ធទាំងនេះទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ នៅពេលណាដែលអនុសញ្ញានេះក្លាយជាកម្មវត្ថុនៃការធ្វើអប្បដិបត្តិកម្មដោយអនុលោមតាមមាត្រា ៣៤ នៃធម្មនុញ្ញរបស់អង្គការអន្តរជាតិខាងការងារ។

## [illegible]

១. នៅកន្លែងណាដែលខ្លឹមសារនៃអនុសញ្ញានេះស្ថិតនៅក្នុងអំណាចស្វ័យគ្រប់គ្រងនៃដែនដីចំណុះប្រទេសជាសមាជិកដែលទទួលខុសត្រូវចំពោះបញ្ហាទំនាក់ទំនងអន្តរជាតិនៃដែនដីនោះ ដោយមានការព្រមព្រៀងជាមួយនឹងរដ្ឋាភិបាលនៃដែនដីចំណុះ អាចធ្វើជូនអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ នូវសេចក្តីប្រកាសយល់ព្រមបំពេញកាតព្វកិច្ចក្នុងអនុសញ្ញានេះក្នុងនាមដែនដីចំណុះនោះ។

២. សេចក្តីប្រកាសយល់ព្រមលើកាតព្វកិច្ចក្នុងអនុសញ្ញានេះ អាចធ្វើជូនទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារដោយ៖

(ក) ប្រទេសជាសមាជិកពីរ ឬលើសពីនេះ ដែលមានទឹកដីសហព័ន្ធស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។

(ខ) អាជ្ញាធរអន្តរជាតិដែលទទួលបន្ទុកគ្រប់គ្រងទឹកដីសហព័ន្ធដោយអនុលោមតាមកតិកាសញ្ញារបស់អង្គការសហប្រជាជាតិ ឬកតិកាសញ្ញាផ្សេងៗទៀតដែលជាប់ពាក់ព័ន្ធនឹងដែនដីទាំងនោះ។

៣. សេចក្តីប្រកាសនានាអនុលោមតាមកថាខណ្ឌខាងលើនៃមាត្រានេះ ដែលត្រូវជូនដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ ត្រូវបញ្ជាក់ថា តើបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះនឹងត្រូវបានគេយកមកអនុវត្តនៅក្នុងដែនដីចំណុះដោយមាន ឬគ្មានការកែប្រែ។ នៅពេលដែលសេចក្តីប្រកាសបញ្ជាក់ថាបទប្បញ្ញត្តិទាំងនោះត្រូវបានគេអនុវត្តដោយមានការកែប្រែសេចក្តីប្រកាសនោះត្រូវមានភ្ជាប់មកជាមួយនូវអត្ថបទពិស្តារស្តីពីហេតុផលនៃការកែប្រែនោះផង។

៤. ប្រទេសជាសមាជិក ឬអាជ្ញាធរអន្តរជាតិដែលពាក់ព័ន្ធ អាចប្រកាសតាមរយៈ

សេចក្តីប្រកាស តាមរយៈសេចក្តីប្រកាសជាបន្ទាប់នូវសិទ្ធិទាំងស្រុង ឬដោយផ្អែកក្នុងការធ្វើឧបាស្រ័យចំពោះការកែប្រែដែលមានចែងនៅក្នុងសេចក្តីប្រកាសកន្លងទៅ។

៥. ប្រទេសជាសមាជិក ឬអាជ្ញាធរអន្តរជាតិដែលមានការពាក់ព័ន្ធត្រូវផ្ញើទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារនូវសេចក្តីប្រកាសបញ្ជាក់អំពីអាណត្តិនៃសេចក្តីប្រកាសកន្លងទៅ ព្រមទាំងបង្ហាញអំពីស្ថានភាពបច្ចុប្បន្នទាក់ទងដល់ការអនុវត្តន៍អនុសញ្ញានេះ ក្នុងករណីដែលអនុសញ្ញានេះអាចជាកម្មវត្ថុនៃការធ្វើអប្បដិបត្តិកម្មដោយអនុលោមតាមមាត្រា ៣៥ នៃធម្មនុញ្ញរបស់អង្គការអន្តរជាតិខាងការងារ។

## មាត្រា [illegible]

សច្ចាប័នជាផ្លូវការនៃអនុសញ្ញានេះ ត្រូវជូនដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារដើម្បីចុះបញ្ជិកា។

## មាត្រា [illegible]

១. អនុសញ្ញានេះត្រូវចាត់ទុកជាកាតព្វកិច្ចចំពោះតែប្រទេសជាសមាជិកនៃអង្គការអន្តរជាតិខាងការងារណាដែលសច្ចាប័នរបស់ខ្លួនត្រូវបានចុះបញ្ជិកាដោយអគ្គនាយកនៃអង្គការនេះ។

២. អនុសញ្ញានេះនឹងចូលជាធរមានក្នុងអំឡុងពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជិកាដោយអគ្គនាយកនៃអង្គការនេះ និងបន្ទាប់ពីការផ្តល់សច្ចាប័ននៃប្រទេសជាសមាជិកចំនួនពីររួចមក។

៣. បន្ទាប់ពីនោះមក អនុសញ្ញានេះនឹងចូលជាធរមានសម្រាប់ប្រទេសជាសមាជិកណាមួយក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជិកាលើការឱ្យសច្ចាប័នរបស់ខ្លួន។

## មាត្រា [illegible]

១. ប្រទេសជាសមាជិកណាមួយ ដែលបានឱ្យសច្ចាប័នអនុសញ្ញានេះរួចហើយ អាចធ្វើអប្បដិបត្តិកម្មអនុសញ្ញានេះ បន្ទាប់ពីការផុតរលត់នៃអំឡុងដប់ឆ្នាំគិតពីកាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមានលើកទី១ ។ ការធ្វើអប្បដិបត្តិកម្មនេះត្រូវធ្វើដោយលិខិតជូនដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារដើម្បីអគ្គនាយកនេះចុះបញ្ជិកា។ អប្បដិបត្តិកម្មនេះនឹងមិនមានសុពលភាពរហូតរយៈពេលមួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃអប្បដិបត្តិកម្មនេះបានចុះបញ្ជិកា។

២. ក្នុងអំឡុងឆ្នាំបន្តបន្ទាប់ពីការផុតរលត់នៃរយៈពេលដប់ឆ្នាំដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ប្រទេសជាសមាជិកនីមួយៗ ទោះជាបានឱ្យសច្ចាប័នអនុសញ្ញានេះក្តី មិនទាន់

បានក្តី ចំពោះការអនុវត្តន៍សិទ្ធិធ្វើអប្បដិបត្តិកម្មដែលបានកំណត់ក្នុងមាត្រានេះត្រូវបញ្ចូលសម្រាប់រយៈពេលដប់ឆ្នាំថ្មីទៀត ហើយបន្ទាប់មកធ្វើអប្បដិបត្តិកម្មអនុសញ្ញានេះក្នុងអំឡុងនៃការផុតរលត់នៃរយៈពេលដប់ឆ្នាំនីមួយៗ តាមលក្ខខណ្ឌដូចបានចែងនៅក្នុងមាត្រានេះរួចហើយ។

## មាត្រា ១៧

១. អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារត្រូវជូនដំណឹងចំពោះគ្រប់ប្រទេសជាសមាជិកទាំងអស់នៃអង្គការនេះអំពីការចុះបញ្ជិកានៃការឱ្យសច្ចាប័ន និងអប្បដិបត្តិកម្មនៃប្រទេសជាសមាជិកដែលបានធ្វើរួចហើយ។

២. នៅពេលដែលជូនដំណឹងទៅប្រទេសជាសមាជិកទាំងអស់អំពីការចុះបញ្ជិកានៃការឱ្យសច្ចាប័នលើកទី ២ អគ្គនាយកត្រូវរំលឹកដល់ប្រទេសទាំងនោះអំពីកាលបរិច្ឆេទដែលអនុសញ្ញានេះនឹងចូលជាធរមាន។

## មាត្រា ១៨

អនុលោមតាមមាត្រា ១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ ត្រូវជូនដំណឹងទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិដើម្បីចុះបញ្ជិកា នូវព័ត៌មានពិស្តារគ្រប់គ្រាន់នៃការឱ្យសច្ចាប័ន និងលិខិតអប្បដិបត្តិកម្មដែលអគ្គនាយកនេះបានចុះបញ្ជិកាអនុលោមតាមបទបញ្ញត្តិនៃមាត្រាបន្តបន្ទាប់ខាងលើ។

## មាត្រា ១៩

នៅពេលដែលពិនិត្យឃើញថាមានការចាំបាច់ ក្រុមប្រឹក្សាភិបាលនៃអង្គការអន្តរជាតិខាងការងារត្រូវធ្វើរបាយការណ៍ជូនសន្និសីទសាកលអំពីដំណើរការអនុវត្តន៍អនុសញ្ញា ព្រមទាំងពិនិត្យលទ្ធភាពដាក់ក្នុងរបៀបវារៈនៃសន្និសីទនូវសំណើសុំពិនិត្យកែលំអខ្លឹមសារនៃអនុសញ្ញាទាំងស្រុង ឬដោយផ្នែកខ្លះ។

## មាត្រា ២០

១. សន្និសីទអាចសំរេចលើអនុសញ្ញាថ្មីមួយដែលកែលំអខ្លឹមសារនៃអនុសញ្ញានេះទាំងស្រុង ឬដោយផ្នែក ហើយវៀរលែងតែអនុសញ្ញាបុនរាព្រឹត្តថ្មីមានកំណត់បទបញ្ញត្តិផ្សេងពីនេះគឺ៖

(ក) ដោយមិនគិតដល់បទបញ្ញត្តិនៃមាត្រា ១៩ ខាងលើ និងប្រសិនបើនៅពេលដែលអនុសញ្ញាថ្មីបានចូលជាធរមាន ការឱ្យសច្ចាប័ននៃប្រទេសជាសមាជិកណាមួយចំពោះអនុសញ្ញាថ្មីមានន័យពេញច្បាប់ ថាប្រទេសនោះបានធ្វើអប្បដិបត្តិកម្មជាស្វ័យប្រវត្តិលើអនុសញ្ញានេះ។

(ខ) ចាប់ពីពេលដែលអនុសញ្ញាថ្មីចូលជាធរមាន អនុសញ្ញានេះនឹងត្រូវឈប់បើកឱ្យប្រទេសជាសមាជិកធ្វើសច្ចាប័នតទៅ។

២. អនុសញ្ញានេះនឹងនៅជាធរមានទាំងទម្រង់ និងខ្លឹមសារជាក់ស្តែងសម្រាប់ប្រទេសជាសមាជិកណាដែលបានឱ្យសច្ចាប័នហើយ ប៉ុន្តែមិនទាន់បានឱ្យសច្ចាប័នចំពោះអនុសញ្ញាកែលំអថ្មី។

## មាត្រា ២១

អត្ថបទបកប្រែជាភាសាអង់គ្លេស និងភាសាបារាំងនៃអនុសញ្ញានេះត្រូវទុកជាបន្ទាល់ដូចគ្នា។

អត្ថបទនេះ គឺជាអត្ថបទយថាភូតមានលក្ខណៈជាអនុសញ្ញាដែលសំរេចដោយសន្និសីទសាកលនៃអង្គការអន្តរជាតិខាងការងារនាសម័យប្រជុំលើកទីសាមសិបមួយ ដែលប្រារព្ធឡើងនៅទីក្រុងហ្សឺណែវ ព្រមទាំងបានប្រកាសបិទនៅថ្ងៃទី ៩ ខែកក្កដា ឆ្នាំ១៩៤៨។

ជាកិច្ចបន្ទាល់ យើងសូមភ្ជាប់មកជាមួយនូវហត្ថលេខាដែលចុះនៅថ្ងៃទី ម្ភៃបី ខែមិថុនា ឆ្នាំ១៩៤៨។

ប្រធានសន្និសីទ

F. ROSALES ARGUELLO

អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ

M. HANSENNE

****************************************